# បង្កើនល្បឿនកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍

ដោយ លោក ច័ន្ទ សុផល អ្នកគ្រប់គ្រងស្រាវជ្រាវជាន់ខ្ពស់ CDRI

1. នៅក្នុង៥ឆ្នាំកន្លងមកនេះ CDRI បានធ្វើការសិក្សាមួយចំនួន ដែលសង្កត់ធ្ងន់លើបញ្ហាភាពក្រីក្រ ។ ការសិក្សាទាំងអស់នេះ បានចង្អុលបង្ហាញនូវរូបភាពមួយច្បាស់លាស់ អំពីកម្ពុជាបច្ចុប្បន្ន និង អំពីវិធីកាត់បន្ថយភាពក្រីក្រ និង អភិវឌ្ឍន៍ ឱ្យបានលឿនជាងមុន ។ ការស្រាវជ្រាវរបស់វិទ្យាស្ថានបានរកឃើញថា មានការរីកចំរើនជាលំដាប់នៅកម្ពុជា ដែលជាការឆ្លុះបញ្ចាំងនូវតួលេខម៉ាក្រូសេដ្ឋកិច្ច ។ ក៏ប៉ុន្តែ យើងក៏មានការបារម្ភផងដែរអំពីរបាយនៃកំណើនសេដ្ឋកិច្ច ដែលភាគច្រើនធ្លាក់ក្នុងកណ្តាប់ដៃអ្នកមានជាងគេមួយចំនួន ត្រូវជា២០ភាគរយនៃប្រជាជន ដូចដែលបានគូសបញ្ជាក់នៅក្នុងឯកសារវាយតំលៃភាពក្រីក្រ របស់ធនាគារពិភពលោក នៅឆ្នាំ ២០០៦ ។ ការណ៏នេះកាន់តែធ្វើឱ្យមានគំលាត រវាងអ្នកមាន និង អ្នកក្រ និង រវាងទីក្រុង និងទីជនបទ ដែលជាការបារម្ភមួយរបស់ភាគីអភិវឌ្ឍន៍ភាគច្រើន ក្នុងពេលបច្ចុប្បន្ន ។ អត្រាភាពក្រីក្រ ៣៥ភាគរយ នៅឆ្នាំ ២០០៤ គឺជាអត្រាខ្ពស់ជាងគេនៅក្នុងចំណោមប្រទេសជាតិខាង ។

2. ជាការមួយគួរឱ្យកត់សំគាល់នោះគឺ មានគ្រួសារមួយចំនួនធំដែលរស់នៅលើបន្ទាត់ភាពក្រីក្រតែបន្តិចប៉ុណ្ណោះ ។ ពួកគេងាយនឹងធ្លាក់ចូលក្នុងភាពក្រីក្រប្រសិនបើពួកគេប៉ះតង្គិចដោយវិបត្តិណាមួយ រួមទាំងបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលកើតមានឡើងជាញឹកញយ នៅក្នុងមួយទស្សវត្សរកន្លងមកនេះ ។ យើងមានការយកចិត្តទុកដាក់ជាពិសេស ចំពោះរបកគំហើញដោយការវាយតំលៃភាពក្រីក្រដោយមានការចូលរួម នៅតំបន់ទន្លេសាប ថា អ្នកក្រីក្រខ្លាំង ជាទូទៅ នៅផុតពីអន្តរាគមន៏ដោយគោលនយោបាយ ដែលនាំឱ្យមានការលំបាកខ្លាំងក្នុងការជួយជីវភាពរបស់ពួកគេ ។

3. យើងមានការត្រេកអរនឹងការរីកចំរើនជារួមកន្លងមក ប៉ុន្តែយើងមានការបារម្ភខ្លាំង អំពីបញ្ហាថ្មីមួយចំនួនដែលកើតមានឡើងហើយ ទំនងជាការតែធ្ងន់ធ្ងរ ប្រសិនបើគ្មានការអភិវឌ្ឍន៏ឆាប់រហ័សជាងនេះ នៅតំបន់ជនបទមួយចំនួន ដែលមានធនធានរួមថយចុះខ្លាំង និង ខ្វះលទ្ធភាពរកការងារធ្វើ ។ បញ្ហាទាំងនេះរួមមាន ការកើនឡើងនូវជំលោះ ការប្រើប្រាស់ទឹក ការទន្ទ្រានយកដីនិងព្រៃ ការកើនឡើងនូវភាពងាយរងគ្រោះ ជាពិសេស ស្ត្រីនៅក្នុងគ្រួសារក្រីក្រខ្លាំង ហានិភ័យចោរកម្ម និង ការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមយុវជន ។

4. ការសិក្សាតាមដានការវិវត្តន៏ក្នុងភូមិចំនួនប្រាំបួន នៅរាយក្នុងប្រទេសកម្ពុជា បានបង្ហាញថា ការកាត់បន្ថយភាពក្រីក្រមានលទ្ធផលខុសគ្នា ពីភូមិមួយទៅភូមិមួយទៀត ។ ខណៈដែលសហគមន៏មួយចំនួន មានការរីកចំរើន នៅក្នុងរយៈពេល ៣-៤ឆ្នាំ មកនេះ សហគមន៏ខ្លះ ស្ថិតនៅដដែល ឬ ក្រជាងមុនទៀតផង ។ ដូចគ្នានេះដែរ មានគ្រួសារខ្លះ បានចាកផុតពីភាពក្រីក្រ នៅខណៈដែលគ្រួសារខ្លះធ្លាក់ចុះក្នុងភាពក្រីក្រ ។ កត្តាដែលបណ្តាលឱ្យមាន ការប្រែប្រួលខុសគ្នានេះ គឺជាការចង្អុលបង្ហាញច្បាស់លាស់សំរាប់ការពិភាក្សាគោលនយោបាយ ។

5. មូលហេតុជាចំបងដែលធ្វើឱ្យសហគមន៏មួយចំនួនរីកចំរើននោះ គឺ (១) កំណើនចំណូលកសិកម្ម ដែលបណ្តាលមកពីបច្ចេកទេសដាំដុះ ប្រព័ន្ធធារាសាស្ត្រ និង ទីផ្សារ មានការប្រសើរជាងមុន (២) កំណើនលទ្ធភាពទៅរកឱកាស

ខាងក្រៅដោយសារមានការរីកចំរើនខាងការអភិវឌ្ឍន៏ផ្លូវថ្នល់ (៣) ការបង្កើនមុខជំនួញតូចតាច មួយចំណែកដោយសារមីក្រូឥណទានមានការរីកចំរើន ។

6. មានមូលហេតុមួយសំខាន់ដែលធ្វើឱ្យសហគមន៍ និង គ្រួសារមួយចំនួនធ្លាក់ចុះ ឬ នៅក្រីក្រខ្លាំងដដែល ។ ព្រៃឈើមានការថយចុះ វិចរឹលយ៉ាងឆាប់រហ័សនៅក្នុងមួយទសវត្សន៏នួងមក ដែលជាចំណែកមួយនៃបរាជ័យក្នុងការអនុវត្តច្បាប់ ។ ស្ថិតិថ្នាក់ជាតិមិនបង្ហាញឱ្យឃើញនូវការថយចុះធនធានត្រីក៏ពិតមែន ក៏ប៉ុន្តែ ធនធាននេះកាន់តែធ្លាក់ចុះទៅ និងបានទៅលើអ្នកមាន ជាពិសេស អ្នកមកពីក្រៅសហគមន៏ ។ អ្នកក្រជួបប្រទះនឹងការថយចុះស្តុកត្រី ។ សហគមន៏ដែលនៅក្បែរព្រៃឈើ និង បឹងទន្លេសាប ច្រើនតែក្រជាងតំបន់ផ្សេងទៀត ។ ដោយសារធនធានរួមដែលនៅសេសសល់ មិនទំនងជាអាចបន្តទ្រទ្រង់ជីវភាពគ្រួសារបានច្រើននោះ តើមានជំរើសអ្វីខ្លះ សំរាប់ពួកគេ ?

7. យើងឃើញថា វិស័យពីរដែលនាំមុខគេ គឺ កាត់ដេរសំលៀកបំពាក់ និង ទេសចរណ៏ មិនបានកាត់បន្ថយភាពក្រីក្របានច្រើនឡើយ ដោយវិស័យទាំងពីរនេះមានចំណងទាក់ទងតិចតួចទៅនឹងការបង្កើតការងារនៅជនបទ ។ ទន្ទឹមនឹងការចង់ឱ្យមានកំណើនបន្ថែមទៀតនៅក្នុងវិស័យទាំងពីរនេះ មានការព្រមព្រៀងគ្នាជាទូទៅថា កសិកម្ម គួរតែជាម៉ាស៊ីន កំណើនសេដ្ឋកិច្ចទីបី ដើម្បីកាត់បន្ថយភាពក្រីក្របានលឿនជាងមុន ។ **<u>នេះគឺជាពេលដែលតំរូវឱ្យមាន ការចាត់វិធានការណ៏ជាក់ស្តែង</u>** ។

8. ការអភិវឌ្ឍន៏កសិកម្ម ទាមទារឱ្យមានធនធានច្រើនថែមទៀតទៅលើវិស័យនេះ ជាពិសេសទៅលើប្រព័ន្ធធារាសាស្ត្រ និង ការស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេស ។ ការលើកកំពស់ការគ្រប់គ្រងដីធ្លី ការកែច្នៃកសិកម្ម និង ទីផ្សារ មានសារៈសំខាន់ខ្លាំងណាស់ ។ ថវិកាចំណាយលើវិស័យកសិកម្ម និង ធារាសាស្ត្រ មានកំរិតទាបណាស់ក្នុងពេលកន្លងមក ។ ជាអាទិ៍ នៅឆ្នាំ ២០០៥ រដ្ឋាភិបាលចំណាយតែ ១៣ លានដុល្លារ ប៉ុណ្ណោះ ក្នុងចំណាយថវិកាសរុបជិត ៨០០ លានដុល្លារ ។ ម្ចាស់ជំនួយផ្តល់តែ ៣៥ លានដុល្លារប៉ុណ្ណោះ ក្នុងជំនួយសរុប ៥០០ លានដុល្លារ ។ ចំណាយរបស់រដ្ឋាភិបាល និង ម្ចាស់ជំនួយលើវិស័យធារាសាស្ត្រ មានតែ ១៣ លានដុល្លារប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០០៥ ដែលជាកំរិតប្រហែលគ្នាក្នុងប៉ុន្មានឆ្នាំកន្លងមក ។

9. មានសក្តានុពលធំណាស់ក្នុងការអភិវឌ្ឍន៏កសិឧស្សាហកម្មនៅកម្ពុជា ។ កន្លងមក វិស័យនេះ នៅមានកំរិតតិចតួចមែនទែន ។ វាជាផ្នែកមួយដែលវិស័យឯកជនអាចរកចំណេញបានច្រើន ប្រសិនបើមានការគាំទ្រដោយគោលនយោបាយរដ្ឋ ។ បច្ចុប្បន្ននេះ ផលិតផលភាគច្រើន ត្រូវបាននាំចេញទៅប្រទេសជិតខាងដើម្បីកែច្នៃ និង នាំចេញបន្ត ។ កម្ពុជាមិនគ្រាន់តែបាត់បង់ឱកាសបង្កើតតំលៃបន្ថែមប៉ុណ្ណោះទេ ប៉ុន្តែ ការនាំចេញរបៀបនេះ មានលក្ខណៈក្រៅផ្លូវការ ហើយប្រឈមនឹងឧបសគ្គជាច្រើន ។ ដោយសារប្រទេសចិនកាន់តែត្រូវការផលិតផលកសិកម្ម កាលានុវត្តភាពក្នុងការរកចំណេញពីកសិឧស្សាហកម្ម មានទំហំធំធេង ។ ក៏ប៉ុន្តែ សំរេចបានសក្តានុពលនេះ មានការចាំបាច់ក្នុងកាត់បន្ថយចំណាយក្នុងការធ្វើអាជីវកម្ម និង ពាណិជ្ជកម្មនៅកម្ពុជា ។ អ្វីដែលរដ្ឋាភិបាលអាចធ្វើបានបន្ថែមទៀតនោះ គឺការកាត់បន្ថយថ្លៃដឹកជញ្ជូន និងការបង់ថ្លៃតាមព្រំដែន ។

10. កម្ពុជា គឺជាប្រទេសមួយមានថ្លៃដឹកជញ្ជូន និង ថ្លៃថាមពលខ្ពស់ ។ តាមការសិក្សា ដោយបណ្តាញស្ថាប័នស្រាវជ្រាវ ក្នុងតំបន់ដែលគ្រប់គ្រងដោយ CDRI ថ្លៃដឹកជញ្ជូនកសិផល (ពោត សណ្តែកសៀង ឬ ដំឡូង) ចំនួន ១ តោន ក្នុងចំងាយផ្លូវ

១០០ គីឡូម៉ែត្រ គឺមាន ១០-១២ដុល្លារ នៅកម្ពុជា ៤-៥ដុល្លារ នៅ វៀតណាម និង ២.៥ ដុល្លារ នៅថៃ ។ លើសពីនេះ ការនាំទំនិញកសិកម្មឆ្លងកាត់ព្រំដែន នៅមានថ្លៃខ្ពស់ និង ការរំខានស្មុគ្រស្មាញច្រើន ។ ឧទាហរណ៍ ក្នុងពោតចំនួន ១០ តោន ថ្លៃបង់សរុប មានពី ៥០ ដល់ ៨០ ដុល្លារ នៅតាមច្រកព្រំដែនកម្ពុជា-ថៃ មួយចំនួន ។ អ្នកនាំទំនិញចេញត្រូវឆ្លងកាត់អាជ្ញាធរមួយចំនួន គឺ ប៉ូលីសអន្តរជាតិ គយ កាំកុងត្រូល ប៉ូលីសសេដ្ឋកិច្ច ទាហាន កងរាជអាវុធហត្ថ អាជ្ញាធរព្រំដែន អង្គភាពសំរបសំរួលព្រំដែនទ្វេរភាគី ។ អង្គភាពមួយចំនួន អាចមានការិយាល័យផ្សេងគ្នាសំរាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់ស្រុក ។

11. ក្នុងការបោះជំហានទៅមុខ កម្ពុជាអាចចាប់យកផលប្រយោជន៏ច្រើនថែមទៀតពីទីផ្សារនៅក្នុងតំបន់ និង ពិភពលោក ។ ការនេះអាចសំរេចបានតាមរយៈការពង្រីកផលិតកម្ម និង វិនិយោគនៅក្នុងកសិឧស្សាហកម្ម និង ការបន្ថយចំណាយ ក្នុងការចរាចរទំនិញ ។ កម្ពុជា អាចប្រើប្រាស់ដីឱ្យមានប្រសិទ្ធិភាពថែមទៀត ទាំងដីចាស់ ទាំងដីថ្មីដែលទើបនឹងអស់ព្រៃ ដោយមានគោលនយោបាយលំអៀងទៅរកអ្នកក្រ តាមរយៈការបង្កើនប្រព័ន្ធធារាសាស្ត្រ ការបែងចែកដីដោយសមធម៌ និង ការអភិវឌ្ឍន៏ច្រកទៅកាន់ទីផ្សារ ។ នៅក្នុងន័យនេះ ដីសម្បទានសេដ្ឋកិច្ចដែលមិនដំណើរការ គួរត្រូវបានពិចារណាវិញច្បាស់លាស់ ។ ការចាប់យកដី និង ទិញដីស្តុកទុក គួរត្រូវបានគ្រប់គ្រងដោយការយកពន្ធលើដីទ្រង់ទ្រាយធំៗ ។ ការធ្វើដូចនេះបាន នឹងអាចសំរេចបាន សក្តានុពលផលិតទំនិញកសិកម្មដើម្បីផ្គត់ផ្គង់ទីផ្សារកំពុងតែកើនឡើងក្នុងតំបន់ និង ការកាត់បន្ថយភាពក្រីក្រ ។ ឧទាហរណ៍ ប្រទេសថៃនាំចេញដំឡូងមីទៅប្រទេសចិន ចំនួន ៥០០លានដុល្លារ ក្នុងឆ្នាំ២០០៥។ វៀតណាមនាំចេញបាន ៥០លានដុល្លារ។ រីឯកម្ពុជានាំចេញប្រហែល ៥ លានដុល្លារប៉ុណ្ណោះ ។ ការសិក្សារបស់យើងរកឃើញថា កម្ពុជា មានសក្តានុពល បង្កើនផលិតកម្ម និងនាំចេញបានលើសពីបច្ចុប្បន្នច្រើនដងណាស់ ប្រសិនបើដីត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព ។

12. ដើម្បីឱ្យផលិតកម្ម និង ពាណិជ្ជកម្មកែច្នៃ និងនាំចេញដំណាំទទួលបានជោគជ័យ គួរមានវិធានការមួយចំនួន ដូចតទៅ :

- លើកទឹកចិត្តដល់វិស័យឯកជនឱ្យមានការវិនិយោគច្រើនថែមទៀត នៅក្នុងកសិឧស្សាហកម្ម
- បែងចែកដីធ្លីឱ្យមានប្រសិទ្ធិភាព និង កាត់បន្ថយថ្លៃប្រតិបត្តិអាជីវកម្ម និង ពាណិជ្ជកម្ម ដោយរួមទាំងថ្លៃដឹកជញ្ជូន និង ថ្លៃបង់តាមព្រំដែន ដើម្បីឱ្យវិនិយោគមានការរីកចំរើន
- ផ្តល់គ្រឿងលើកទឹកចិត្ត ឬប្រាក់បៀវត្សដល់មន្ត្រីសាធារណៈ ដើម្បីឱ្យពួកគេសំរួលការប្រឹងប្រែងរបស់ឯកជន ឬ មិនរំខានដល់ពួកគេ

13. ទស្សនវិស័យរបស់ CDRI ក្នុងការបន្ថយភាពក្រីក្រ គឺ កម្ពុជាមានការរីកចំរើន និង កាត់បន្ថយភាពក្រីក្រ បានឆាប់ហ៊័សជាងមុន ដោយសារ ការប្រែក្លាយសក្តានុពលរបស់ខ្លួន និង សក្តានុពលក្នុងតំបន់ ឱ្យទៅជាការពិត ។ អនាគតគឺនៅក្នុងដៃរបស់យើង ។ តើយើងទាំងអស់គ្នា ទាំងរាជរដ្ឋាភិបាល ទាំងវិស័យឯកជន ទាំងម្ចាស់ជំនួយ និង សង្គមស៊ីវិល អាចធ្វើការរួមគ្នា ដូចម្តេចខ្លះ ដើម្បីសំរេចបាននូវគោលបំណងរួម គឺជាការបន្ថយភាពក្រីក្រ និង អភិវឌ្ឍន៏ បានឆាប់រហ័សជាងមុន ?